*(អត្ថបទបកប្រែក្រៅផ្លូវការ)*

# សេចក្តីថ្លែងការណ៍រួមរវាងព្រះរាជាណាចក្រកម្ពុជា និងជប៉ុន

តបតាមការអញ្ជើញរបស់រដ្ឋាភិបាលជប៉ុន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** អមដំណើរដោយ**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** បានអញ្ជើញបំពេញទស្សនកិច្ចការងារផ្លូវការនៅប្រទេសជប៉ុន ពីថ្ងៃទី២៨ ដល់ ៣១ ខែឧសភា ឆ្នាំ២០២៥។ នៅក្នុងជំនួបកំពូលទ្វេភាគី នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង**ឯកឧត្តម អ៊ិស៊ីបាក់ ស៊ីហ្គេរី** នាយករដ្ឋមន្ត្រីនៃប្រទេសជប៉ុន បានបញ្ជាក់អំពីសារៈសំខាន់នៃការពង្រីក និងធ្វើឱ្យកាន់តែស៊ីជម្រៅនូវ «ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ» រវាងប្រទេសទាំងពីររួមមាន សហបង្កើតគុណតម្លៃសេដ្ឋកិច្ច និងសង្គម និងកិច្ចសហប្រតិបត្តិការសន្តិសុខផ្អែកលើទំនុកចិត្ត និងមិត្តភាពដែលប្រទេសទាំងពីរបានកសាងជាច្រើនឆ្នាំកន្លងមក។ ភាគីទាំងពីរក៏បានឯកភាពធ្វើការជាមួយគ្នាបន្ថែមទៀតដើម្បីរក្សា និងពង្រឹងសណ្តាប់ធ្នាប់អន្តរជាតិផ្អែកលើនីតិរដ្ឋ ក៏ដូចជាប្រព័ន្ធពាណិជ្ជកម្មសេរីពហុភាគី។

## ១. សហបង្កើតគុណតម្លៃសេដ្ឋកិច្ច និងសង្គម

នាយករដ្ឋមន្ត្រីទាំងពីរបានស្វាគមន៍នូវវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការជាក់ស្តែង រួមមាន «សហបង្កើតសម្រាប់គំនិតផ្តួចផ្តើមរបៀបវារៈរួម» ក្នុងវិស័យឌីជីថល ចាប់តាំងពីការបង្កើត «អភិក្រមថ្មីចំនួនបីនៃកិច្ចសហប្រតិបត្តិការ» កាលពីខែកក្កដាកន្លងទៅ ដែលរួមមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គមក្នុងវិស័យទឹក និងឌីជីថល ការតភ្ជាប់តាមផ្លូវសមុទ្រ និងសកម្មភាពមីនមនុស្សធម៌។

នាយករដ្ឋមន្ត្រីទាំងពីរបានប្រកាសដាក់ចេញនូវ «កញ្ចប់សហបង្កើតសេដ្ឋកិច្ចជប៉ុន-កម្ពុជា» ដូចមានភ្ជាប់ជាមួយ និងបានឯកភាពគ្នាក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការបន្ថែមទៀត ដូចជាការកែលម្អបរិយាកាសធុរកិច្ចនៅកម្ពុជា តាមរយៈការចូលរួមចំណែករបស់ជប៉ុនចំពោះអង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) ការគាំទ្រក្រុមហ៊ុនជប៉ុន ការបង្កើតគម្រោងភាពជាដៃគូរដ្ឋ-ឯកជន និងការគាំទ្រការធ្វើឱ្យរីកចម្រើនបណ្តាញទូរគមនាគមន៍ ដើម្បីពង្រឹងឧស្សាហកម្ម និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់។

នាយករដ្ឋមន្ត្រីទាំងពីរបានបញ្ជាក់ថា ការអភិវឌ្ឍកំពង់ផែក្រុងព្រះសីហនុ រួមចំណែកដល់ការតភ្ជាប់ក្នុងតំបន់ និងជំរុញពាណិជ្ជកម្ម ព្រមទាំងបានបញ្ជាក់សាជាថ្មីក្នុងការបន្តកិច្ចសហប្រតិបត្តិការ ដើម្បីរក្សា និងអភិវឌ្ឍកំពង់ផែនេះទៅជាកំពង់ផែស្នូល និងមជ្ឈមណ្ឌលភស្តុភារកម្មក្នុងតំបន់។ ភាគីទាំងពីរក៏បានអះអាងសាជាថ្មី ក្នុងការជំរុញកិច្ចសហប្រតិបត្តិការ ដើម្បីពង្រឹងសមត្ថភាពនគរបាលការពារព្រំដែនទឹកកម្ពុជា និងគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ។

នាយករដ្ឋមន្ត្រីទាំងពីរបានផ្លាស់ប្តូរយោបល់គ្នាការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។ **នាយករដ្ឋមន្ត្រី អ៊ីស៊ីបាក់** បានបង្ហាញពីបំណងរបស់ជប៉ុនក្នុងការបន្តគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា តាមរយៈការផ្តល់ជំនួយបច្ចេកទេសផ្នែកច្បាប់ និងការគាំទ្រដល់ការបោះឆ្នោត ក៏ដូចជាការចែករំលែកបទពិសោធន៍របស់ជប៉ុនអំពីលទ្ធិប្រជាធិបតេយ្យ។ **សម្តេចធិបតីនាយករដ្ឋមន្ត្រី**បានថ្លែងអំណរគុណចំពោះការបន្តគាំទ្រដ៏មានតម្លៃរបស់ជប៉ុនក្នុងវិស័យនេះ ហើយបានបង្ហាញពីបំណងក្នុងការខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីបញ្ចូលលទ្ធផលនៃការគាំទ្រទាំងនេះទៅក្នុងសង្គមកម្ពុជា។ ក្នុងន័យនេះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក៏បានវាយតម្លៃចំពោះតួនាទីរបស់ជប៉ុនក្នុងនាមជាអ្នករៀបចំសេចក្តីសម្រេចចិត្តស្តីពីសេវាផ្តល់យោបល់ និងជំនួយបច្ចេកទេសសម្រាប់កម្ពុជា នៅក្រុមប្រឹក្សាសិទ្ធិមនុស្ស។

នាយករដ្ឋមន្ត្រីទាំងពីរបានបញ្ជាក់ថា ការផ្លាស់ប្តូររវាងប្រជាជន និងប្រជាជនក្នុងវិស័យធុរកិច្ច ទេសចរណ៍ ស្រាវជ្រាវអប់រំ ស្ថាប័ន កីឡា និងការផ្លាស់ប្តូរវប្បធម៌ បង្កើតជាមូលដ្ឋាននៃទំនាក់ទំនងសហបង្កើតរវាងប្រទេសទាំងពីរ ហើយបានបង្ហាញពីគោលបំណងក្នុងការជំរុញការផ្លាស់ប្តូរខាងលើបន្ថែមទៀតនៅកម្រិតរដ្ឋាភិបាល។ ភាគីទាំងពីរយល់ថា ព្រឹត្តិការណ៍ Expo2025 នៅអូសាកា កាន់សៃ ប្រទេសជប៉ុន និង GREEN×EXPO 2027 នឹងក្លាយជាឱកាសដ៏ល្អ ដើម្បីជំរុញការផ្លាស់ប្តូរ និងអះអាងសាជាថ្មីក្នុងការបង្កើនកិច្ចសហប្រតិបត្តិការ។

## ២. កិច្ចសហប្រតិបត្តិការសន្តិសុខ

ដោយពិចារណាលើការផ្លាស់ប្តូរដ៏យូរអង្វែងរវាងកងទ័ពជើងគោកកម្ពុជា និងកងកម្លាំងស្វ័យការពារជើងគោកជប៉ុន នាយករដ្ឋមន្ត្រីទាំងពីរបានបង្ហាញពីបំណងក្នុងការជំរុញកិច្ចសហប្រតិបត្តិការលើវិស័យសន្តិសុខបន្ថែមទៀត។ **សម្តេចធិបតីនាយករដ្ឋមន្ត្រី**បានស្វាគមន៍ជប៉ុន ដែលបានតែងតាំងអនុព័ន្ធយោធាអមស្ថានទូតជប៉ុនប្រចាំនៅកម្ពុជាឡើងវិញ។ នាយករដ្ឋមន្ត្រីទាំងពីរបានបង្ហាញក្តីរំពឹងចំពោះភាពរលូននៃកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរទ្វេភាគីលើវិស័យការពារជាតិ ក៏ដូចជាការប្រាស្រ័យទាក់ទងគ្នា រួមទាំងការពិចារណាលើគម្រោងជំនួយសន្តិសុខផ្លូវការ នាពេលអនាគត។ នាយករដ្ឋមន្ត្រីទាំងពីរបានសម្តែងការស្វាគមន៍ដែលប្រទេសទាំងពីរបាននិងកំពុងរួមចំណែកក្នុងការរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ តាមរយៈការកសាងសមត្ថភាពក្នុងការថែរក្សាសន្តិភាពក្រោមកម្មវិធីភាពជាដៃគូត្រីភាគីរបស់អង្គការសហប្រជាជាតិ (TPP)។

**សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានស្វាគមន៍ចំពោះទស្សនកិច្ចសុច្ឆន្ទៈរបស់នាវាកងកម្លាំងស្វ័យការពារជើងទឹកជប៉ុន (JMSDF) នៅមូលដ្ឋានសមុទ្ររាម ពីថ្ងៃទី១៩ ដល់២២ ខែមេសា ឆ្នាំនេះ ដែលជានាវាកងទ័ពជើងទឹកបរទេសដំបូងគេចូលចតនៅកំពង់ផែនេះ បន្ទាប់ពីបញ្ចប់ការជួសជុលរួច ដោយ**នាយករដ្ឋមន្ត្រី អ៊ីស៊ីបាក់** បានវាយតម្លៃខ្ពស់ចំពោះកម្ពុជា ដែលបានអនុញ្ញាតឱ្យនាវាជប៉ុនចូលចតនេះ។ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានបង្ហាញពីបំណងស្វាគមន៍ការចូលចតនាវារបស់បណ្តាប្រទេសជាមិត្ត នៅមូលដ្ឋានសមុទ្ររាម។

## ៣. ការដោះស្រាយបញ្ហាឆ្លងដែន

នាយករដ្ឋមន្ត្រីទាំងពីរបានទទួលស្គាល់ថា បញ្ហាឆ្លងដែននានា ដូចជាការឆបោកតាមប្រព័ន្ធអនឡាញ (ការបោកប្រាស់តាមប្រព័ន្ធអនឡាញ និងតាមទូរស័ព្ទ) ការលេងល្បែងខុសច្បាប់ ការជួញដូរមនុស្ស ការសម្អាតប្រាក់ និងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំងផ្សេងៗទៀត ព្រមទាំងគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ការបំពុលខ្យល់ និងការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាដែលមិនអាចដោះស្រាយបានដោយប្រទេសមួយតែឯងនោះទេ។ នាយករដ្ឋមន្ត្រីទាំងពីរក៏បានគូសបញ្ជាក់ជាមួយនឹងការព្រួយបារម្ភផងដែរអំពីការកើនឡើងនៃការលួចរូបិយប័ណ្ណគ្រីបតូ និងការផ្ដល់ហិរញ្ញប្បទានដល់សកម្មភាពបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (ICT) ខុសច្បាប់ដោយប្រើរូបិយប័ណ្ណគ្រីបតូ ដែលអាចប៉ះពាល់ដល់សន្តិសុខអន្តរជាតិ។ ភាគីទាំងពីរបានឯកភាពអំពីភាពចាំបាច់នៃកិច្ចសហប្រតិបត្តិការទ្វេភាគី និងក្នុងតំបន់ រួមមានតាមរយៈក្របខ័ណ្ឌមួយចំនួនដូចជា កិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន អាស៊ាន-ជប៉ុន និងសហគមន៍បំភាយឧស្ម័នកម្រិតសូន្យអាស៊ី (AZEC) ហើយបានណែនាំឱ្យអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ក្នុងការចាត់វិធានការនានាប្រកបដោយប្រសិទ្ធភាព ដូចជាការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

## ៤. កិច្ចសហប្រតិបត្តិការលើឆាកអន្តរជាតិ

នាយករដ្ឋមន្ត្រីទាំងពីរបានអះអាងសាជាថ្មីអំពីការគោរពអធិបតេយ្យជាតិ និងបូរណភាពទឹកដី ស្របតាមគោលបំណង និងគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ និងសម្ដែងនូវបំណងពង្រឹងកិច្ចសហ-ប្រតិបត្តិការបន្ថែមទៀត ដើម្បីឈានទៅសម្រេចបាននូវឥណ្ឌូ-ប៉ាស៊ីហ្វិកសេរី និងបើកចំហ ដែលគាំទ្រដល់ឯកភាព និងមជ្ឈភាពរបស់អាស៊ាន និងស្របតាមធម្មនុញ្ញអាស៊ាន និងទស្សនវិស័យអាស៊ានស្ដីពីឥណ្ឌូ-ប៉ាស៊ីហ្វិក ព្រមទាំងរក្សាសណ្ដាប់ធ្នាប់អន្តរជាតិដោយឈរលើនីតិរដ្ឋ។ ផ្អែកលើការទទួលស្គាល់រួមគ្នាចំពោះ «សេចក្ដីថ្លែងការណ៍រួមរវាងព្រះរាជាណាចក្រកម្ពុជា និងជប៉ុន» ចេញផ្សាយកាលពីខែមីនា ឆ្នាំ២០២២ នាយករដ្ឋមន្ត្រីទាំងពីរបានអះអាងសាជាថ្មីក្នុងការបន្តកិច្ចសហប្រតិបត្តិការជិតស្និទ្ធ ដើម្បីលើកកម្ពស់សន្តិភាព ស្ថិរភាព និងវិបុលភាពក្នុងតំបន់ និងពិភពលោក។

នាយករដ្ឋមន្ត្រីទាំងពីរបានយល់ឃើញដូចគ្នាអំពីសារៈសំខាន់នៃភាពធន់សេដ្ឋកិច្ច និងសន្តិសុខសេដ្ឋកិច្ច រួមមានការពង្រឹងខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងតំបន់ ព្រមទាំងបានឯកភាពគ្នាបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការរក្សា និងពង្រឹងសណ្ដាប់ធ្នាប់សេដ្ឋកិច្ចអន្តរជាតិផ្អែកលើវិធានច្បាប់ដែលសេរី និងយុត្តិធម៌ សំដៅរួមចំណែកដល់កំណើនប្រកបដោយស្ថិរភាព ចីរភាព និងបរិយាបន្ន។

ដោយមើលឃើញបទពិសោធន៍របស់កម្ពុជាក្នុងដំណើរការសន្តិភាព និងការស្ដារប្រទេសជាតិឡើងវិញ **នាយករដ្ឋមន្ត្រី អ៊ិស៊ីបាក់** បានស្វាគមន៍ចំពោះតួនាទីជាសកលរបស់កម្ពុជា រួមមានការចូលរួមចំណែករបស់កងទ័ពមួកខៀវកម្ពុជាក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ (PKO) និងកិច្ចសហប្រតិបត្តិការ

តាមរយៈសន្និសីទស្តីពីកិច្ចសហប្រតិបត្តិការក្នុងចំណោមប្រទេសអាស៊ីបូព៌ាសម្រាប់ការអភិវឌ្ឍប៉ាឡេស្ទីន (CEAPAD)។ នាយករដ្ឋមន្ត្រីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការកម្ពុជា-ជប៉ុន ក្នុងការដោះស្រាយបញ្ហាប្រឈមអន្តរជាតិនានា ដូចជាការបណ្តុះបណ្តាលអ្នកដោះមីនរបស់អ៊ុយក្រែន ក្នុងគោលបំណងមនុស្សធម៌ តាមរយៈកិច្ចសហប្រតិបត្តិការត្រីភាគី ដោយកម្ពុជាដើរតួជាមជ្ឈមណ្ឌលបណ្តុះបណ្តាល ព្រមទាំងការទទួលស្វាគមន៍គណៈប្រតិភូប៉ាឡេស្ទីនធ្វើទស្សនកិច្ចនៅតំបន់សេដ្ឋកិច្ចកម្ពុជា ដើម្បីស្វែងយល់ពីបទពិសោធន៍របស់កម្ពុជា ក្នុងការអភិវឌ្ឍនប្រទេសក្រោយសង្គ្រាម។ នាយករដ្ឋមន្ត្រីទាំងពីរបានអះអាងសាជាថ្មីក្នុងការបង្កើនបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការ ដើម្បីស្វែងរកសន្តិភាព និងស្ថិរភាពអន្តរជាតិ។

ចំពោះស្ថានភាពនៅឧបទ្វីបកូរ៉េ នាយករដ្ឋមន្ត្រីទាំងពីរបានសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការបន្តបាញ់មីស៊ីលបាលីស្ទីករបស់សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ និងបានអំពាវនាវឱ្យសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ គោរពឱ្យបានពេញលេញតាមសេចក្តីសម្រេចចិត្តទាំងអស់របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។ ភាគីទាំងពីរបានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃកិច្ចសន្ទនាដោយសន្តិវិធី ក្នុងគោលបំណងសម្រេចបាននូវស្ថិរភាព និងសន្តិភាពយូរអង្វែងនៅឧបទ្វីបកូរ៉េ និងបញ្ជាក់សាជាថ្មីអំពីកិច្ចខិតខំប្រឹងប្រែងជាលក្ខណៈអន្តរជាតិ និងមធ្យោបាយការទូត ដើម្បីសម្រេចបាននូវការលុបបំបាត់ទាំងស្រុង ដែលអាចផ្ទៀងផ្ទាត់បាន និងមិនឱ្យមានអាវុធនុយក្លេអ៊ែរនៅឧបទ្វីបកូរ៉េ ស្របតាមសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិដែលពាក់ព័ន្ធ ព្រមទាំងបានអះអាងសាជាថ្មីពីការប្តេជ្ញាចិត្តអនុវត្តឱ្យបានពេញលេញនូវសេចក្តីសម្រេចចិត្តទាំងនេះ។ **នាយករដ្ឋមន្ត្រី អ៊ិស៊ីបាក់** បានថ្លែងអំណរគុណចំពោះការប្តេជ្ញាចិត្តរបស់**សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក្នុងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងនានា ដើម្បីឱ្យមានដំណោះស្រាយបន្ទាន់ចំពោះបញ្ហាចាប់ពង្រត់ជនជាតិជប៉ុន។

ចំពោះស្ថានភាពមីយ៉ាន់ម៉ា នាយករដ្ឋមន្ត្រីទាំងពីរបានគូសបញ្ជាក់ពីសារៈសំខាន់នៃការផ្តល់ជំនួយមនុស្សធម៌ដែលផ្តល់ផលប្រយោជន៍ដោយផ្ទាល់ដល់ប្រជាជនមីយ៉ាន់ម៉ា ដែលទទួលរងការខូចខាតដោយសារគ្រោះរញ្ជួយដី ដែលបានកើតឡើងកាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៥។ ភាគីទាំងពីរក៏បានឯកភាពថាការបន្ត និងការអនុវត្តឱ្យបានពេញលេញនូវបទឈប់បាញ់ដោយគ្រប់ភាគីពាក់ព័ន្ធ គឺជាការចាំបាច់ដើម្បីសម្រេចគោលបំណងនេះ។ នាយករដ្ឋមន្ត្រីទាំងពីរក៏បានសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងចំពោះស្ថានភាពនៅមីយ៉ាន់ម៉ា ដោយសារជីវភាពរបស់ប្រជាជនមីយ៉ាន់ម៉ាជាច្រើនត្រូវបានរងផលប៉ះពាល់យ៉ាងខ្លាំង។ **នាយករដ្ឋមន្ត្រី អ៊ិស៊ីបាក់** បានបញ្ជាក់សាជាថ្មីអំពីការគាំទ្ររបស់ជប៉ុនចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អាស៊ាន រួមមានការអនុវត្ត «ការព្រមព្រៀងជាឯកច្ឆន្ទ៥ចំណុច» ស្របពេលដែលទទួលស្គាល់សារៈសំខាន់នៃឯកភាព និងមជ្ឈភាពរបស់អាស៊ាន។ នាយករដ្ឋមន្ត្រីទាំងពីរបានអំពាវនាវឱ្យបញ្ឈប់ជាបន្ទាន់នូវអំពើហិង្សានៅមីយ៉ាន់ម៉ា និងឱ្យមានកិច្ចសន្ទនាប្រកបដោយភាពស្មោះត្រង់រវាងភាគីពាក់ព័ន្ធទាំងអស់ តាមរយៈដំណើរការនយោបាយមួយដែលមីយ៉ាន់ម៉ាជាម្ចាស់ និងដឹកនាំដោយមីយ៉ាន់ម៉ា។

ចំពោះស្ថានភាពនៅសមុទ្រចិនខាងត្បូង នាយករដ្ឋមន្ត្រីទាំងពីរបានទទួលស្គាល់អំពីអត្ថប្រយោជន៍នៃសមុទ្រចិនខាងត្បូង ដែលជាសមុទ្រនៃសន្តិភាព ស្ថិរភាព និងវិបុលភាព។ នាយករដ្ឋមន្ត្រីទាំងពីរបានអះអាងសាជាថ្មីអំពីសារៈសំខាន់នៃការរក្សាសន្តិភាព សន្តិសុខ សុវត្ថិភាព សេរីភាព នៃការធ្វើនាវាចរណ៍នៅ និងការហោះហើរពីលើសមុទ្រចិនខាងត្បូង ការអត់ធ្មត់រៀងៗខ្លួន ភាពគ្មានយោធូបនីយកម្ម និងការដោះស្រាយជម្លោះដោយសន្តិវិធី ដោយអនុលោមតាមច្បាប់អន្តរជាតិ រួមទាំងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ (UNCLOS) ឆ្នាំ១៩៨២។ នាយករដ្ឋមន្ត្រីទាំងពីរក៏បានអះអាងសាជាថ្មីអំពីភាពចាំបាច់ក្នុងការពង្រឹងទំនុកចិត្ត និងការជឿជាក់ទៅវិញទៅមក ប្រកាន់ការអត់ធ្មត់នៅក្នុងការធ្វើសកម្មភាពនានា ដែលធ្វើឱ្យជម្លោះកាន់តែតានតឹង ឬស្មុគ្រស្មាញ និងប៉ះពាល់ដល់សន្តិភាព និងស្ថិរភាព ព្រមទាំងចៀសវាងសកម្មភាពណាដែលអាចធ្វើឱ្យសភាពការណ៍កាន់តែស្មុគស្មាញថែមទៀត។ នាយករដ្ឋមន្ត្រីទាំងពីរបានសង្កត់ធ្ងន់ពីសារៈសំខាន់នៃការអនុវត្តឱ្យបានពេញលេញ និងមានប្រសិទ្ធភាពនូវសេចក្តីថ្លែងការណ៍ស្តីពីការប្រតិបត្តិរបស់ភាគីនៅសមុទ្រចិនខាងត្បូង (DOC) និងបានស្វាគមន៍វឌ្ឍនភាពនៃការចរចាលើក្រមប្រតិបត្តិសមុទ្រចិនខាងត្បូង (COC) និងបានគូសបញ្ជាក់ពីសារៈសំខាន់នៃការបញ្ចប់ការចរចាឱ្យបានឆាប់ នូវ COC ប្រកបដោយប្រសិទ្ធភាព និងមានអត្ថន័យ ដែលស្របតាមច្បាប់អន្តរជាតិ រួមទាំង UNCLOS ឆ្នាំ ១៩៨២។

នាយករដ្ឋមន្ត្រីទាំងពីរបានទទួលស្គាល់អំពីភាពចាំបាច់ក្នុងការធ្វើកំណែទម្រង់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ដើម្បីដោះស្រាយបញ្ហាប្រឈមជាសកលដ៏ធ្ងន់ធ្ងរ ហើយបានបញ្ជាក់ជាថ្មីអំពីការប្តេជ្ញាចិត្តក្នុងការបន្តកិច្ចសហប្រតិបត្តិការដើម្បីសម្រេចកិច្ចការនេះ។ **នាយករដ្ឋមន្ត្រី អ៊ិស៊ីបាក់** បានថ្លែងអំណរគុណកម្ពុជា ចំពោះការបន្តគាំទ្រការធ្វើកំណែទម្រង់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ រួមទាំងការគាំទ្រប្រទេសជប៉ុន ដើម្បីក្លាយជាសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សានេះ។

-----------------

*( បកប្រែក្រៅផ្លូវការ )*

# ភាពជាដៃគូសហការបង្កើតសេដ្ឋកិច្ចកម្ពុជា-ជប៉ុន

១. <u>ការរៀបចំសិក្ខាសាលាធុរកិច្ចនៅប្រទេសជប៉ុន និងនៅប្រទេសជិតខាងរបស់កម្ពុជា ព្រមទាំងការរៀបចំបេសកកម្មនៅក្នុងវិស័យយុទ្ធសាស្ត្រ</u>

១.១. ការរៀបចំសិក្ខាសាលាធុរកិច្ចនៅប្រទេសជប៉ុន និងនៅប្រទេសជិតខាងរបស់កម្ពុជា

- ស្ថាប័នរបស់កម្ពុជា៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ស្ថាប័នរបស់ជប៉ុន៖ អង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន ( JETRO )

១.២. ការបញ្ជូនបេសកកម្មធុរកិច្ច មកកម្ពុជា

- ស្ថាប័នរបស់កម្ពុជា៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ស្ថាប័នរបស់ជប៉ុន៖ JETRO

២. <u>កិច្ចសហប្រតិបត្តិការបច្ចេកទេស សម្រាប់រៀបចំក្រុមសហបង្កើតធុរកិច្ច</u>

២.១. ការអនុវត្តកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍធនធានមនុស្ស សម្រាប់រៀបចំក្រុមសហបង្កើតធុរកិច្ច

- ស្ថាប័នរបស់កម្ពុជា៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ស្ថាប័នរបស់ជប៉ុន៖ ក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម ( METI ) និង JETRO

៣. <u>ការអភិវឌ្ឍធនធានមនុស្សលើវិស័យឧស្សាហកម្មដែលមានជំនាញខ្ពស់ ដោយសម្របសម្រួលជាមួយគ្រឹះស្ថានបណ្តុះបណ្តាល និងសាកលវិទ្យាល័យក្នុងស្រុក</u>

៣.១. ការអភិវឌ្ឍធនធានមនុស្សកម្រិតខ្ពស់ រៀបចំដោយមជ្ឈមណ្ឌលផលិតកម្មឌីជីថលកម្ពុជា-ជប៉ុន ( CJDM )

- ស្ថាប័នរបស់កម្ពុជា៖ មជ្ឈមណ្ឌលផលិតកម្មឌីជីថលកម្ពុជា-ជប៉ុន នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ( RUPP-CJDM )
- ស្ថាប័នរបស់ជប៉ុន៖ ក្រសួងការបរទេស ( MOFA ), METI និង គណៈកម្មាធិការសហប្រតិបត្តិការឧស្សាហកម្ម និងសេដ្ឋកិច្ច នៃ ASEAN Economic Ministers-METI ( AMEICC )

៣.២. ការលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សនៅតាមសាលាបណ្តុះបណ្តាលវិជ្ជាជីវៈរបស់កម្ពុជា

- ស្ថាប័នរបស់កម្ពុជា៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ស្ថាប័នរបស់ជប៉ុន៖ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ( JICA )

៣.៣. ការលើកកម្ពស់ការធានាចំពោះការអភិវឌ្ឍធនធានមនុស្សកម្រិតខ្ពស់ តាមរយៈការពង្រឹងកិច្ចសហការរវាងក្រុមហ៊ុន និងសាកលវិទ្យាល័យនានា តាមរយៈការផ្តល់ថវិការៀបចំវគ្គសិក្សា និងការស្រាវជ្រាវរួមគ្នាជាដើម

- ស្ថាប័នរបស់កម្ពុជា៖ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ស្ថាប័នរបស់ជប៉ុន៖ METI និង JICA

៣.៤. ការពង្រឹងមុខងាររបស់មជ្ឈមណ្ឌលផ្លាស់ប្តូរធុរកិច្ច នៃមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC)

- ស្ថាប័នរបស់កម្ពុជា៖ ក្រសួងអប់រំ យុវជន និងកីឡា និង CJCC នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- ស្ថាប័នរបស់ជប៉ុន៖ JICA

៣.៥. ការគាំទ្រប្រព័ន្ធគ្រប់គ្រងការបំពុលបរិស្ថាន

- ស្ថាប័នរបស់កម្ពុជា៖ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ស្ថាប័នរបស់ជប៉ុន៖ METI និង សមាគមគ្រប់គ្រងបរិស្ថានសម្រាប់ឧស្សាហកម្មជប៉ុន (JEMAI)

៤. <u>កិច្ចសហប្រតិបត្តិការផ្សេងៗសម្រាប់ការកែលម្អបន្ថែមនូវបរិយាកាសកស្តុភារកម្ម រួមទាំងភស្តុភារកម្មឆ្លងដែន</u>

៤.១. ការវិភាគគុណភាព និងបរិមាណនៃបរិយាកាសកស្តុភារកម្មនៅកម្ពុជា

- ស្ថាប័នរបស់កម្ពុជា៖ ក្រសួងសាធារណការ និងដឹកជញ្ជូន
- ស្ថាប័នរបស់ជប៉ុន៖ ក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន និងទេសចរណ៍ (MLIT) និង JICA

៤.២. ការពង្រឹងសមត្ថភាពអនុវត្ត និងលើកកម្ពស់ការបង្កើនសមត្ថភាពដឹកជញ្ជូន តាមរយៈហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក

- ស្ថាប័នរបស់កម្ពុជា៖ ក្រសួងសាធារណការ និងដឹកជញ្ជូន
- ស្ថាប័នរបស់ជប៉ុន៖ MLIT, MOFA និង JICA

៤.៣. ការបង្កើតវេទិកាពិភាក្សា ដើម្បីសម្របសម្រួលផ្នែកកស្តុភារកម្មជាមួយរដ្ឋាភិបាលនៃបណ្តាប្រទេសមេគង្គ រួមទាំងការអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងដែនជាដើម

- ស្ថាប័នរបស់កម្ពុជា៖ ក្រសួងពាណិជ្ជកម្ម
- ស្ថាប័នរបស់ជប៉ុន៖ JICA និង AMEICC

៤.៤. ការអភិវឌ្ឍធនធានមនុស្សសម្រាប់អាជ្ញាធររៀបចំគោលនយោបាយនៃបណ្តាប្រទេសមេគង្គ

- ស្ថាប័នរបស់កម្ពុជា៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ស្ថាប័នរបស់ជប៉ុន៖ JICA និង ក្រសួងហិរញ្ញវត្ថុ (MOF)

៥. <u>ការបង្កើតបរិយាកាសវិនិយោគ និងលទ្ធកម្មសម្រាប់ក្របខ័ណ្ឌនៃការប្រើប្រាស់ថាមពលបៃតង ដូចជាសហគមន៍បំភាយឧស្ម័នកម្រិតសូន្យអាស៊ី (AZEC)</u>

៥.១. ការផ្លាស់ប្តូរយោបល់ឆ្ពោះទៅរកការបង្កើត និងការលើកកម្ពស់ប្រព័ន្ធផ្សេងៗ (ពន្ធ និងឧបត្ថម្ភធន) សម្រាប់ផ្ទាំងដំបូលសូឡា

- ស្ថាប័នរបស់កម្ពុជា៖ ក្រសួងរ៉ែ និងថាមពល និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ស្ថាប័នរបស់ជប៉ុន៖ METI និង វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA)

៥.២. ការផ្លាស់ប្តូរយោបល់ឆ្ពោះទៅរកការបង្កើតប្រព័ន្ធផ្តល់វិញ្ញាបនប័ត្រសម្រាប់ថាមពលកកើតឡើងវិញ

- ស្ថាប័នរបស់កម្ពុជា៖ ក្រសួងរ៉ែ និងថាមពល
- ស្ថាប័នរបស់ជប៉ុន៖ METI និង ERIA

៥.៣. ការបង្កើតផែនទីបង្ហាញផ្លូវរយៈពេលវែង ដើម្បីសម្រេចបាននូវសង្គមមានភាពអព្យាក្រឹតកាបូន

- ស្ថាប័នរបស់កម្ពុជា៖ ក្រសួងរ៉ែ និងថាមពល
- ស្ថាប័នរបស់ជប៉ុន៖ JICA

៥.៤. ការផ្លាស់ប្តូរយោបល់ ដើម្បីជំរុញគម្រោងជាក់លាក់ស្តីពីអន្តរកាលនៃការកាត់បន្ថយកាបូន

- ស្ថាប័នរបស់កម្ពុជា៖ ក្រសួងរ៉ែ និងថាមពល
- ស្ថាប័នរបស់ជប៉ុន៖ METI

៦. <u>កិច្ចសហប្រតិបត្តិការផ្សេងៗដែលរួមចំណែកដល់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចឌីជីថល</u>

៦.១. ការបង្កើតប្រព័ន្ធគមនាគមន៍ដែលបើកចំហ និងមានសុវត្ថិភាព (រួមទាំងការបង្ហាញសាកល្បងប្រព័ន្ធ RAN)

- ស្ថាប័នរបស់កម្ពុជា៖ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ស្ថាប័នរបស់ជប៉ុន៖ ក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ (MIC)

៦.២. ការលើកកម្ពស់ឌីជីថលនីយកម្មក្នុងប្រព័ន្ធរដ្ឋបាល

- ស្ថាប័នរបស់កម្ពុជា៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ស្ថាប័នរបស់ជប៉ុន៖ MOFA, JICA, MLIT និង MIC

៦.៣. ការពង្រឹងវិធានការសន្តិសុខសាយប័រ

- ស្ថាប័នរបស់កម្ពុជា៖ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ស្ថាប័នរបស់ជប៉ុន៖ MIC និង JICA

៧. <u>អនុវិស័យ៖ ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសថ្មី</u>

៧.១. ការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងតំបន់សេដ្ឋកិច្ចពិសេសថ្មី រួមទាំងតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តភ្នំពេញ

- ស្ថាប័នរបស់កម្ពុជា៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ស្ថាប័នរបស់ជប៉ុន៖ MOFA និង JICA

៨. <u>កិច្ចសហប្រតិបត្តិការតាមរយៈអង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD)</u>

៨.១. ការលើកកម្ពស់បរិយាកាសវិនិយោគ តាមរយៈការរួមចំណែករបស់ប្រទេសជប៉ុនចំពោះ OECD

- ស្ថាប័នរបស់កម្ពុជា៖ ក្រសួងពាណិជ្ជកម្ម
- ស្ថាប័នរបស់ជប៉ុន៖ MOFA

៨.២. "សិក្ខាសាលាសហបង្កើត" ស្តីពីកញ្ចប់ឧបករណ៍បញ្ញាសិប្បនិម្មិត

- ស្ថាប័នរបស់កម្ពុជា៖ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ស្ថាប័នរបស់ជប៉ុន៖ MOFA និង MIC

៩. <u>ផ្សេងៗ</u>

៩.១. ការកសាងសមត្ថភាពសម្រាប់មន្ត្រីកម្មសិទ្ធិបញ្ញា

- ស្ថាប័នរបស់កម្ពុជា៖ ក្រសួងពាណិជ្ជកម្ម និង ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ស្ថាប័នរបស់ជប៉ុន៖ ការិយាល័យប្រកាសនីយបត្រតក្កកម្មជប៉ុន

៩.២. ការកសាងសមត្ថភាព ដើម្បីលើកកម្ពស់ប្រព័ន្ធហិរញ្ញវត្ថុរបស់សហគ្រាសធុនតូច និងមធ្យម (SME) តាមរយៈការកែលម្អប្រតិបត្តិការឥណទានរបស់ធនាគារ SME

- ស្ថាប័នរបស់កម្ពុជា៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ធនាគារ SME កម្ពុជា
- ស្ថាប័នរបស់ជប៉ុន៖ វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយ MOF និងក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុជប៉ុន នៃអង្គភាពធុរកិច្ចមីក្រូ និងលក្ខណៈបុគ្គល

----------------